# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ


**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
Ministry of Industry, Science, Technology & Innovation

លេខ: ០៦០ MISTI / ២០២១

# ប្រកាស
## ស្តីពី
## នីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីការផ្តល់ការការពារគំនូរឧស្សាហកម្មដែលរកឃើញ និងច្នៃប្រឌិត ហើយបានចុះបញ្ជីការពារគំនូរឧស្សាហកម្ម នៅព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម និងកិច្ចព្រមព្រៀងទីក្រុងហេច ទាក់ទងនឹងការចុះបញ្ជីគំនូរឧស្សាហកម្មអន្តរជាតិ ៖




ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- លើកទឹកចិត្តចំពោះការច្នៃប្រឌិតនូវគំនូរឧស្សាហកម្មថ្មីៗ
- ជំរុញ និងលើកទឹកចិត្តការធ្វើពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស និងការវិនិយោគ
- លើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិជ្ជាមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយសម្រួលសកម្មភាពឧស្សាហកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច
- ផ្តល់ការការពារចំពោះសិទ្ធិនៃគំនូរឧស្សាហកម្ម និងប្រឆាំងចំពោះការរំលោភសិទ្ធិខាងលើ ក៏ដូចជាប្រឆាំងនឹងការធ្វើជំនួញមិនស្របច្បាប់។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់៖

- អំពីនីតិវិធីក្នុងការចុះបញ្ជីគំនូរឧស្សាហកម្ម និងការចុះបញ្ជីសាឡើងវិញ
- បែបបទនៃការបដិសេធ និងការប្រកាសអាទិភាព នៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម
- សមត្ថកិច្ចនៃការត្រួតពិនិត្យសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម
- នីតិវិធីសវនាការ និងយន្តការដោះស្រាយទំនាស់។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកបង្កើតគំនូរឧស្សាហកម្មថ្មី រូបវន្តបុគ្គល ឬនីតិបុគ្គល និងផ្តល់សិទ្ធិដល់អ្នកបង្កើតស្នាដៃធ្វើអាជីវកម្មលើគំនូរឧស្សាហកម្មរបស់ខ្លួនដែលបានចុះបញ្ជីរួច មានសិទ្ធិប្តឹងទៅតុលាការចំពោះអ្នករំលោភលើគំនូរឧស្សាហកម្មរបស់ខ្លួនដែលបានចុះបញ្ជីរួចនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ប្រកាសនេះត្រូវចាត់ទុកជាបទបញ្ជានៃការអនុវត្តច្បាប់ ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម អនុលោមតាមមាត្រា ១៣០ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម។

**ប្រការ៥.-**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវទទួលពិនិត្យសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម និងចុះបញ្ជីគំនូរឧស្សាហកម្ម ដើម្បីការពារកម្មសិទ្ធិបញ្ញា របស់អ្នកបង្កើតស្នាដៃគំនូរឧស្សាហកម្ម អនុលោមតាមច្បាប់។

**ប្រការ៦.-**

នៅក្នុងប្រកាសនេះពាក្យដូចខាងក្រោមត្រូវបានបកស្រាយ ៖

- **ច្បាប់** គឺច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ។
- **រដ្ឋមន្ត្រី** គឺរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។
- **មន្ត្រីកាន់កាប់បញ្ជី** គឺប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ១៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

- **នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** គឺនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។

- **អនុសញ្ញាទីក្រុងប៉ារីស** គឺអនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស ស្តីពី ការការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣ ហើយបានកែសម្រួលចុងក្រោយ។

- **សំណុំលិខិតស្នើសុំដំបូង** គឺជាសំណុំលិខិតស្នើសុំដែលបានដាក់មុន ឬបានសុំចុះបញ្ជីមុន។

## ផ្នែកទី២
## នីតិវិធីចុះបញ្ជីគំនូរឧស្សាហកម្ម

**ប្រការ៧.-**

មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តតាមចំណាត់ថ្នាក់អន្តរជាតិ នៃគំនូរឧស្សាហកម្មដែលបានអនុម័ត ក្រោមកិច្ចព្រមព្រៀងទីក្រុងឡូកាណូ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៦៨ ហើយបានកែសម្រួលបោះពុម្ពជាបន្តបន្ទាប់សម្រាប់បម្រើគោលបំណងពាក់ព័ន្ធនឹងការចុះបញ្ជី និងការបោះពុម្ពផ្សាយគំនូរឧស្សាហកម្ម ដើម្បីងាយស្រួលក្នុងការស្រាវជ្រាវរកឯកសារដែលបានរក្សាទុកតាមចំណាត់ថ្នាក់។

**ប្រការ៨.-**

សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

១- អនុលោមតាមមាត្រា ៩៥ នៃច្បាប់ សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដែលរួមមាន ពាក្យសុំ, គំនូសបង្ហាញ, រូបថត ឬគំនូសតាងសមស្របផ្សេងៗទៀត ជាតំណាងនៃវត្ថុ ដែលបង្កើតឡើងពីគំនូរឧស្សាហកម្ម និងការចង្អុលបង្ហាញប្រភេទផលិតផល ដែលគំនូរឧស្សាហកម្មត្រូវបានយកមកប្រើប្រាស់ ត្រូវដាក់នៅនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ហើយត្រូវបង់កម្រៃសេវាសាធារណៈតាមការកំណត់។

២- ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមគំរូពាក្យសុំលេខ ១គឧ ដែលមានភ្ជាប់ក្នុង ឧបសម្ព័ន្ធ "ក" នៃប្រកាសនេះ។

៣- សំណុំលិខិតស្នើសុំ ត្រូវបញ្ជាក់អំពីឈ្មោះ អាសយដ្ឋាន សញ្ជាតិ ទីលំនៅ របស់អ្នកដាក់ពាក្យសុំម្នាក់ៗ និងត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ។

៤- ក្នុងករណីអ្នកដាក់ពាក្យសុំជាអ្នកបង្កើតស្នាដៃ ពាក្យសុំត្រូវតែភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់អំពីអានុភាពនោះ ហើយក្នុងករណីដែលអ្នកដាក់ពាក្យសុំ មិនមែនជាអ្នកបង្កើតស្នាដៃទេនោះ ពាក្យសុំត្រូវមានបញ្ជាក់អំពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកបង្កើតស្នាដៃ ពោលគឺអ្នកគូរគំនូរឧស្សាហកម្មម្នាក់ៗ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារដែលបញ្ជាក់អំពីសិទ្ធិរបស់អ្នកដាក់ពាក្យសុំ ចំពោះការចុះបញ្ជីគំនូរឧស្សាហកម្ម។

៥- ប្រសិនបើអ្នកដាក់ពាក្យសុំត្រូវតំណាងដោយភ្នាក់ងារ ពាក្យសុំត្រូវបញ្ជាក់ផងដែរអំពីឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារនោះ។

៦- ការស្នើសុំដោយអ្នកដាក់ពាក្យសុំសម្រាប់ពន្យារពេលនៃការបោះពុម្ពផ្សាយគំនូរឧស្សាហកម្ម ឬគំនូរដែលមាននៅក្នុងសំណុំលិខិតស្នើសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជាក់អំពីរយៈពេលនៃការសុំពន្យារនោះ។

**ប្រការ៩.-**

ចំនួន និងទំហំនៃគំនូរបង្ហាញ ឬរូបថត និងរូបសំណាកតាងឱ្យរូបពិត ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

១- សំណុំលិខិតស្នើសុំត្រូវតែភ្ជាប់មកជាមួយនូវ ៖

ក- គំនូរបង្ហាញ ឬរូបថត ឬរូបសំណាកតាងឱ្យរូបពិត ឬក្រាហ្វិចតាង ចំនួនបួន(៤)ច្បាប់ ប្រសិនបើ គំនូរឧស្សាហកម្មជាទម្រង់ពីរខ្នាត ឬ

ខ- គំនូរបង្ហាញ ឬរូបថត ឬក្រាហ្វិចតាង ចំនួនបួន(៤)ច្បាប់ នៃផ្នែកខុសៗគ្នានីមួយៗ របស់គំនូរឧស្សាហកម្ម និងផ្តល់គំហើញនៃផ្នែកខុសគ្នានីមួយៗនោះ យ៉ាងតិចប្រាំមួយ(៦)គំហើញ ប្រសិនបើគំនូរឧស្សាហកម្មជាទម្រង់បីខ្នាត (3D) និង

គ- គំនូរបោះពុម្ពនៅលើសន្លឹកក្រដាសដែលមិនត្រូវមានខ្នាតធំលើសពីទំហំ ១៧ស.មx២៦ស.មឡើយ។

២- រូបសំណាកតាងឱ្យរូបពិតរបស់គំនូរឧស្សាហកម្ម មិនត្រូវមានខ្នាតធំលើសពីទំហំ ១៥ស.ម x ១៥ស.ម x ១៥ស.ម ឡើយ។ គំនូរបង្ហាញ ឬរូបថត ឬក្រាហ្វិចតាង នៃគំនូរឧស្សាហកម្ម មិនត្រូវមានខ្នាតធំ លើសពីទំហំ ១០ស.ម x ១៥ស.ម ឡើយ។ គំនូសតាងគំនូសបង្ហាញ ឬគំនូសចម្លងតាមទាំងនោះ ត្រូវគូសនៅលើក្រដាសរឹង ដែលមានទំហំអា៤ ចំនួនបួន(៤)សន្លឹក។ គំនូសបង្ហាញ និងគំនូរចម្លងតាម ត្រូវគូរដោយទឹកខ្មៅពណ៌ខ្មៅ។

## ប្រការ១០.-

ចំពោះពាក្យសុំចុះបញ្ជីផ្នែកនៃគំនូរឧស្សាហកម្ម ត្រូវពិពណ៌នាឱ្យបានច្បាស់នូវចំណងជើងគំនូរឧស្សាហកម្មទាំងមូល មិនមែនឈ្មោះផ្នែកនៃគំនូរឧស្សាកម្ម ដែលចង់បានការការពារនោះទេ។ ចំពោះគំនូរបង្ហាញ ឬរូបថតនៃ ផ្នែកនៃគំនូរឧស្សាហកម្ម ត្រូវរំលេចដោយខ្សែជាប់ ឬពណ៌ នៅត្រង់ចំនុចដែលចង់ទទួលបានការការពារ និងរំលេចដោយខ្សែដាច់ត្រង់ចំណុចដែលមិនចង់ទទួលបានការការពារ ចំពោះទំហំគំនូរបង្ហាញ ឬរូបថតត្រូវអនុវត្តដូចប្រការ ៩ ។

## ប្រការ១១.-

ភាសានៃឯកសារ និងការបកប្រែ ត្រូវអនុវត្តដូចខាងក្រោម ៖

១- សំណុំលិខិតស្នើសុំ និងឯកសារណាមួយដែលបង្កើតបានជាផ្នែកមួយនៃសំណុំលិខិតស្នើសុំ ឬឯកសារណាមួយបានដាក់ជូននាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ឬមន្ត្រីកាន់កាប់បញ្ជី អនុលោមតាមច្បាប់ និងប្រកាសនេះ រួមទាំងបទបញ្ជាដែលពាក់ព័ន្ធត្រូវធ្វើជាភាសាខ្មែរ។

២- សម្រាប់គោលបំណងនៃការស្រាវជ្រាវ និងការពិនិត្យក្នុងករណីសំណុំលិខិតស្នើសុំ និងឯកសារ ដូចមានចែងក្នុងចំណុច១ នៃប្រការនេះ ដែលបានសរសេរជាភាសាខ្មែរ ឬជាភាសាបរទេសក្រៅពីភាសាអង់គ្លេស ត្រូវបកប្រែជាភាសាអង់គ្លេស ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី។

៣- សម្រាប់គោលបំណងនៃការវិនិច្ឆ័យ ការការពារ និងការអនុវត្តច្បាប់ ក្នុងករណីសំណុំលិខិតស្នើសុំដែលសរសេរជាភាសាបរទេសក្រៅពីភាសាខ្មែរ ត្រូវបកប្រែជាភាសាខ្មែរហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការសុំចុះបញ្ជី។

## ប្រការ១២.-

ការបញ្ជាក់ឈ្មោះ សញ្ជាតិ អាសយដ្ឋាន និងលំនៅដ្ឋាន ត្រូវបញ្ជាក់ដូចខាងក្រោម ៖

១- ត្រង់ចំណុចឈ្មោះរបស់រូបវន្តបុគ្គលត្រូវបញ្ជាក់ដោយនាមត្រកូល នាមខ្លួន សញ្ជាតិ និងអាសយដ្ឋានរបស់បុគ្គលនោះ។ ឈ្មោះរបស់នីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញជាផ្លូវការរបស់នីតិបុគ្គលនោះ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

២- ត្រង់ចំណុចសញ្ជាតិត្រូវបញ្ជាក់ឈ្មោះប្រទេសដែលបុគ្គលនោះជាជនជាតិ។ នីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះប្រទេសដែលនីតិបុគ្គលនោះត្រូវបានបង្កើតនៅក្រោមច្បាប់នៃប្រទេសនោះ ព្រមទាំងការិយាល័យដែលបាន ចុះបញ្ជីរួចហើយរបស់នីតិបុគ្គលនោះ។

៣- ត្រង់ចំណុចអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ត្រូវបញ្ជាក់តាមវិធីណាមួយដើម្បីបំពេញការតម្រូវជាធម្មតាសម្រាប់ការបញ្ជូនតាមប្រៃសណីយ៍ ឬមធ្យោបាយផ្សេងទៀតឱ្យបានទាប់ទៅដល់អាសយដ្ឋានដែលបញ្ជាក់នោះ ហើយក្នុងករណីណាមួយក៏ដោយ ក៏ត្រូវបញ្ជាក់ផងដែរនូវអង្គភាពរដ្ឋបាលពាក់ព័ន្ធរួមទាំងលេខផ្ទះ ប្រសិនបើមាន។ អាសយដ្ឋានត្រូវមានបញ្ជាក់ លេខទូរស័ព្ទ លេខទូរសារ និងអាសយដ្ឋានអ៊ីម៉ែលផងដែរ។

៤- ត្រង់ចំណុចលំនៅដ្ឋាន ត្រូវបានបញ្ជាក់ឈ្មោះប្រទេស ដែលបុគ្គលនោះជាជនមានលំនៅដ្ឋានជាប់លាប់។

៥- គ្រប់អ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវដាក់ឱ្យមន្ត្រីកាន់កាប់បញ្ជីនូវអាសយដ្ឋានសម្រាប់ទំនាក់ទំនងនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់គោលបំណងនៃសំណុំលិខិតស្នើសុំរបស់គាត់។

**ប្រការ១៣.-**

ការប្តូរឈ្មោះ សញ្ជាតិ និងអាសយដ្ឋាន ត្រូវអនុវត្តដូចខាងក្រោម ៖

១- សំណើសុំដោយម្ចាស់ ឬដោយអ្នកដាក់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដើម្បីប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទងដែលបានកត់ត្រាចំពោះគំនូរឧស្សាហកម្ម ឬនៅក្នុងសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្មរបស់ខ្លួន ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

២- មុននឹងអនុវត្តតាមសំណើក្នុងការប្តូរឈ្មោះ ឬសញ្ជាតិ មន្ត្រីកាន់កាប់បញ្ជីអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំផ្តល់កស្តុតាងសមស្របពាក់ព័ន្ធទៅនឹងការប្តូរនេះ។

៣- ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា សំណើនោះសមស្រប មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្ត ការប្តូរនោះលើគំនូរឧស្សាហកម្ម ឬក៏លើសំណុំលិខិតស្នើសុំការចុះបញ្ជីគំនូរឧស្សាហកម្ម ហើយក្នុងករណីដែលឈ្មោះ សញ្ជាតិ ឬអាសយដ្ឋាន ត្រូវបានកត់ត្រារួចហើយនៅក្នុងបញ្ជី បញ្ជីនោះក៏ត្រូវតែកត់ត្រាការប្តូរនោះឱ្យបានត្រឹមត្រូវ។

**ប្រការ១៤.-**

ការចុះហត្ថលេខាត្រូវអនុវត្តដូចខាងក្រោម ៖

១- ឯកសារដែលរៀបចំដើម្បីចុះហត្ថលេខាជួសមុខឱ្យ ឬក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវមានឈ្មោះរបស់ក្រុមហ៊ុន និងដៃគូទាំងអស់ ជាឈ្មោះពេញ ហើយត្រូវបានចុះហត្ថលេខាដោយអ្នកទាំងអស់នោះ ឬដោយដៃគូណាមួយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចុះហត្ថលេខា ដោយបញ្ជាក់ថា ដៃគូនោះចុះហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬចុះហត្ថលេខា ដោយបុគ្គលណាម្នាក់ផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារ។ ឯកសារដែលបានរៀបចំដើម្បីចុះហត្ថលេខាជួសមុខឱ្យ ឬក្នុងនាមអង្គភាពសាជីវកម្ម ត្រូវចុះហត្ថលេខាដោយនាយក ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ណាមួយផ្សេងទៀតរបស់អង្គភាពសាជីវកម្មនោះ ឬដោយបុគ្គលណាមួយផ្សេងទៀត ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថាបុគ្គលនោះត្រូវបានអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារ និងប្រថាប់ត្រារបស់អង្គភាពសាជីវកម្មនោះផង។ ឯកសារដែលរៀបចំឡើងដើម្បីចុះហត្ថលេខាជួសមុខឱ្យ ឬក្នុងនាមសមាគមនៃបុគ្គលច្រើននាក់ អាចត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ ដើម្បីចុះហត្ថលេខា។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

២- ក្នុងករណីដែលយល់ថាចាំបាច់ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើសុំឱ្យផ្តល់ភស្តុតាងនៃការអនុញ្ញាតឱ្យចុះហត្ថលេខា។

**ប្រការ១៥.-**

ការប្រកាសអះអាងអាទិភាព នៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម យោងតាមមាត្រា ១០០ នៃច្បាប់ ត្រូវអនុវត្តដូចខាងក្រោម ៖

១- សេចក្តីប្រកាសដែលបានអះអាង យោងតាមមាត្រា ២៧ នៃច្បាប់ ត្រូវធ្វើឡើងនៅពេលដាក់សំណុំលិខិត ស្នើសុំគំនូរឧស្សាហកម្ម ហើយត្រូវបញ្ជាក់អំពី ៖

ក- កាលបរិច្ឆេទនៃការសុំចុះបញ្ជីរបស់សំណុំលិខិតស្នើសុំដំបូង។

ខ- លេខនៃសំណុំលិខិតស្នើសុំដំបូង លើកលែងតែចំណុច ២ នៃប្រការនេះ។

គ- និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម ដែលត្រូវបានដាក់ចំពោះសំណុំលិខិតស្នើសុំដំបូង លើកលែងតែចំណុច ៣ នៃប្រការនេះ។

ឃ- ឈ្មោះប្រទេសដែលបានទទួលការសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំដំបូង ឬឈ្មោះប្រទេសមួយ ឬច្រើន ដែលបានទទួលការសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំ នៅក្នុងករណីដែលសំណុំលិខិតស្នើសុំដំបូង ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬជាសំណុំលិខិតស្នើសុំអន្តរជាតិ។

ង- ឈ្មោះការិយាល័យដែលបានទទួលការសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំដំបូង ក្នុងករណីសំណុំ លិខិតស្នើសុំដំបូង ជាសំណុំលិខិតស្នើសុំថ្នាក់តំបន់ ឬជាសំណុំលិខិតស្នើសុំអន្តរជាតិ។

២- ក្នុងករណីពេលដាក់សេចក្តីប្រកាស ដូចមានចែងនៅក្នុងចំណុច ១ នៃប្រការនេះ លេខនៃសំណុំលិខិតស្នើសុំដំបូង មិនត្រូវបានដឹងទេនោះ លេខនេះត្រូវតែផ្តល់ឱ្យក្នុងរយៈពេលបី(៣)ខែក្រោយកាលបរិច្ឆេទ នៃការដាក់សំណុំលិខិតស្នើសុំ នៅនាយកដ្ឋានទទួលបន្ទុកកម្មសិទ្ធិ និងត្រូវបានទទួលស្គាល់សម្រាប់ការសុំចុះបញ្ជី។

៣- ក្នុងករណីពេលដាក់សេចក្តីប្រកាស ដូចមានចែងនៅក្នុងចំណុច ១ នៃប្រការនេះ និមិត្តសញ្ញារបស់ចំណាត់ថ្នាក់អន្តរជាតិនៃគំនូរឧស្សាហកម្ម មិនត្រូវបានកំណត់ឱ្យ ចំពោះសំណុំលិខិតស្នើសុំដំបូង ឬមិនទាន់បានកំណត់ឱ្យនៅឡើយ អ្នកដាក់ពាក្យសុំត្រូវថ្លែងបញ្ជាក់អំពីហេតុការណ៍នេះ នៅក្នុងសេចក្តីប្រកាសនេះ ហើយត្រូវផ្តល់និមិត្តសញ្ញានេះយ៉ាងឆាប់ តាមកាលកំណត់។

៤- អ្នកដាក់ពាក្យសុំអាចកែតម្រូវអត្ថបទ នៃសេចក្តីប្រកាសដូចមានចែងនៅក្នុងចំណុច ១ នៃប្រការនេះនាពេលណាមួយមុនការចុះបញ្ជីគំនូរឧស្សាហកម្ម។

៥- យោងតាមមាត្រា ២៨ នៃច្បាប់ រយៈពេលសម្រាប់ការផ្តល់ឯកសារចម្លង ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម នៃសំណុំលិខិតស្នើសុំដំបូង ដល់មន្ត្រីកាន់កាប់បញ្ជីត្រូវមានរយៈពេលបី(៣)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំ។ ក្នុងករណីដែលឯកសារចម្លងនៃសំណុំលិខិតស្នើសុំ ត្រូវបានប្រគល់រួចហើយសម្រាប់ការដាក់សំណុំលិខិតស្នើសុំផ្សេងទៀត អ្នកដាក់ពាក្យសុំអាចឆ្លើយតបដោយធ្វើសេចក្តីយោងទៅលើការដាក់សំណុំលិខិតផ្សេងទៀតនោះ។

៦- ក្នុងករណីសំណុំលិខិតស្នើសុំដំបូង សរសេរជាភាសាផ្សេង ក្រៅពីភាសាខ្មែរ អ្នកដាក់ពាក្យសុំត្រូវផ្តល់សេចក្តីបកប្រែនៃសំណុំលិខិតស្នើសុំនោះ ជាភាសាខ្មែរ ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំរបស់មន្ត្រីកាន់កាប់បញ្ជី។

៧- ទោះបីជាគ្មានការស្នើសុំពីមន្ត្រីកាន់កាប់បញ្ជីក៏ដោយ ក៏អ្នកដាក់ពាក្យសុំត្រូវតែផ្តល់ឱ្យនូវសំណុំលិខិតស្នើសុំដំបូង ចំនួនមួយ(១)ច្បាប់ ជាមួយសេចក្តីបកប្រែសំណុំលិខិតនោះចំនួនមួយ(១)ច្បាប់។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ១៦.-**

ការដកហូតយកទៅវិញ និងការកែតម្រូវសំណុំលិខិតស្នើសុំ ត្រូវអនុវត្តដូចខាងក្រោម ៖

១- សំណុំលិខិតស្នើសុំ អាចសុំដកយកវិញទៅបាន ដោយសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ហើយដែលបានចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ឬភ្នាក់ងារតំណាង។

២- កម្រៃសេវាដែលពាក់ព័ន្ធនឹងការដាក់សំណុំលិខិតស្នើសុំ មិនត្រូវបានប្រគល់ឱ្យវិញទេ ប្រសិនបើសំណុំលិខិតស្នើសុំត្រូវបានដកយកទៅវិញ។

៣- ការកែតម្រូវណាមួយនៃសំណុំលិខិតស្នើសុំ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

៤- សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ដែលត្រូវបានដកហូតយកទៅវិញ បានបោះបង់ចោល ឬត្រូវបានបដិសេធ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ៤(គ)(៤) ស្តីពីសិទ្ធិអាទិភាព នៃអនុសញ្ញាក្រុងប៉ារីស តាមការសមស្រប។

**ប្រការ១៧.-**

ការចុះលេខ និងការគូសសញ្ញា ត្រូវអនុវត្តដូចខាងក្រោម ៖

១- នៅពេលដែលទទួលសំណុំលិខិតស្នើសុំ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សម្គាល់ នៅលើឯកសារនីមួយៗនៃសំណុំលិខិតស្នើសុំ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួល និងលេខសំណុំលិខិតស្នើសុំ ដែលផ្តុំដោយអក្សរ " កជ " បន្ទាត់ទ្រេត "/" អក្សរ "គឧ" បន្ទាត់ទ្រេត "/" លេខបួនខ្ទង់ចុងក្រោយនៃឆ្នាំ ដែលឯកសារត្រូវបានទទួល បន្ទាត់ទ្រេត "/" និងលេខចំនួនប្រាំខ្ទង់ ដែលត្រូវដាក់តាមលំដាប់លំដោយនៃសំណុំលិខិតស្នើសុំ ដែលបានទទួលក្នុងឆ្នាំនីមួយៗ។ ក្នុងករណីដែលឯកសារកែតម្រូវណាមួយ ឬឯកសារដែលបានដាក់ក្រោយផ្សេងទៀត ត្រូវបានទទួលនៅលើកាលបរិច្ឆេទខុសគ្នា មន្ត្រីកាន់កាប់បញ្ជីត្រូវចុះកំណត់សម្គាល់ផងដែរ នូវកាលបរិច្ឆេទជាក់ស្តែងនៃការទទួលនោះនៅកន្លែងសមស្របរបស់ពាក្យសុំចុះបញ្ជីគំនូរឧស្សាហកម្ម។

២- លេខសំណុំលិខិតស្នើសុំដែលមានចែងក្នុងចំណុចទី១ នៃប្រការនេះ ត្រូវស្រង់យកមកដាក់នៅក្នុងការទាក់ទងព័ត៌មាន តាមលំដាប់លំដោយពាក់ព័ន្ធទៅនឹងសំណុំលិខិតស្នើសុំ។

**ប្រការ១៨.-**

បន្ទាប់ពីអនុវត្តតាមការចែងក្នុងប្រការ១៣ នៃប្រកាសនេះរួចហើយ ត្រូវអនុវត្តបន្តដូចខាងក្រោម ៖

១- មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យថាតើ សំណុំលិខិតស្នើសុំបំពេញត្រឹមត្រូវតាមការតម្រូវ របស់មាត្រា ៩៥ នៃច្បាប់ ឬទេ។

២- ការអញ្ជើញឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវណាមួយតាមវាក្យខណ្ឌទី ២ នៃមាត្រា ១០១ នៃច្បាប់ រួមជាមួយគ្នានិងមាត្រា ៣៤ នៃច្បាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ ការអញ្ជើញ ត្រូវមានបញ្ជាក់អំពីការកែតម្រូវ ឬការតម្រូវឱ្យកែ ហើយស្នើឱ្យដាក់ពាក្យសុំធ្វើការកែតម្រូវនោះ ក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញនោះ។

៣- នៅពេលយល់ព្រមលើកាលបរិច្ឆេទសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ។ ប្រសិនបើសំណុំលិខិតស្នើសុំ ត្រូវបានចាត់ទុកថាមិនត្រូវទទួលចុះបញ្ជី ដូចមានចែងក្នុងមាត្រា ១០១



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

នៃច្បាប់ រួមជាមួយគ្នា និងមាត្រា ៣៤ នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យសុំ ដោយមានបញ្ជាក់ពីមូលហេតុផង។

៤- ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ៨៩ មាត្រា ៩០ មាត្រា ៩៣ មាត្រា ៩៥ និងមាត្រា ៩៦ នៃច្បាប់ និងបទប្បញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងមាត្រាទាំងនេះមិនបានបំពេញត្រឹមត្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើជាលាយលក្ខណ៍អក្សរ ឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអញ្ជើញ ជាមួយនឹងការបង់កម្រៃពាក្យសុំតាមការកំណត់។ ប្រសិនបើអ្នកដាក់ពាក្យសុំ មិនបានអនុវត្តត្រឹមត្រូវតាមការអញ្ជើញឱ្យធ្វើការកែតម្រូវនូវកំហុស ដែលមាននៅក្នុងសំណុំលិខិតស្នើសុំទេនោះ ឬថ្វីបើអ្នកដាក់ពាក្យសុំបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជីនូវការកែតម្រូវរួចហើយក៏ដោយ ក្នុងករណីមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថា លក្ខខណ្ឌខាងលើមិនត្រូវបានបំពេញត្រឹមត្រូវទេនោះ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធសំណុំលិខិតស្នើសុំ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យសុំ ដោយបញ្ជាក់អំពីមូលហេតុផង។

៥- ការបដិសេធសំណុំលិខិតស្នើសុំ មិនមានឥទ្ធិពលដល់កាលបរិច្ឆេទសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំដែលនៅតែរក្សាសុពលភាពដដែល។

៦- មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យសុំអំពីការសម្រេចយល់ព្រមចុះបញ្ជី ឬអំពីការសម្រេចបដិសេធសំណុំលិខិតស្នើសុំ ហើយក្នុងករណីដែលសម្រេចចុះបញ្ជីសំណុំលិខិតស្នើសុំ មន្ត្រីកាន់កាប់បញ្ជីត្រូវស្នើឱ្យអ្នកដាក់ពាក្យសុំ បង់កម្រៃក្នុងការចុះបញ្ជីក្នុងរយៈពេលមួយ(១)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹង។

រាល់ការយឺតយ៉ាវក្នុងការបង់កម្រៃការចុះបញ្ជី ដូចមានចែងក្នុងវាក្យខណ្ឌទី១ អ្នកដាក់ពាក្យសុំ ឬភ្នាក់ងារតំណាងត្រូវបញ្ជាក់មូលហេតុជាលាយលក្ខណ៍អក្សរឱ្យបានច្បាស់លាស់ អំពីការយឺតយ៉ាវនោះដល់មន្ត្រីកាន់កាប់បញ្ជី។ ការយឺតយ៉ាវក្នុងការបង់កម្រៃការចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបានអនុញ្ញាតយ៉ាងយូរចំនួនបី(៣)ខែ។

**ប្រការ១៩.-**

ការចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវអនុវត្តដូចខាងក្រោម ៖

១- អាស្រ័យដោយការបង់កម្រៃក្នុងការចុះបញ្ជី តាមរយៈពេលដែលបានកំណត់ក្នុងចំណុច ៦ នៃប្រការ១៥ នៃប្រកាសនេះ មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការចុះបញ្ជីគំនូរឧស្សាហកម្មនោះ ស្របតាមមាត្រា ១០៣ នៃច្បាប់ និងប្រកាសនេះ។

២- មន្ត្រីកាន់កាប់បញ្ជីត្រូវចុះលេខសម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្មនីមួយៗ ទៅតាមលំដាប់លំដោយនៃការចុះបញ្ជី។

៣- ការចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវរួមបញ្ចូលការបង្ហាញអំពីគំនូរឧស្សាហកម្ម និងត្រូវបញ្ជាក់អំពី ៖

ក- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ

ខ- ឈ្មោះ គំនូរឧស្សាហកម្ម

គ- ប្រសិនបើកាលបរិច្ឆេទអាទិភាពនោះនៅប្រទេសមួយ ឬប្រទេសច្រើនដែលបានទទួលការសុំចុះបញ្ជីនៃសំណុំលិខិតស្នើសុំដំបូង ត្រូវបានអះអាង និងសេចក្ដីអះអាងត្រូវបានទទួលយកកាលបរិច្ឆេទ

ឃ- ប្រភេទនៃផលិតផលដែលគំនូរឧស្សាហកម្មត្រូវយកទៅប្រើប្រាស់។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

៤- ការបោះពុម្ពផ្សាយនៃសេចក្តីយោងចំពោះការចុះបញ្ជីនៃគំនូរឧស្សាហកម្ម អនុលោមតាមមាត្រា ១០៣ នៃច្បាប់ ត្រូវបញ្ជាក់ចំណុចពិសេសៗដូចមានចែងក្នុងចំណុច ៣ នៃប្រការនេះ។

**ប្រការ២០.-**

ការចុះបញ្ជីសាឡើងវិញនៃគំនូរឧស្សាហកម្ម ត្រូវអនុវត្តដូចខាងក្រោម ៖

១- អនុលោមតាមមាត្រា ១០៩ នៃច្បាប់ ការចុះបញ្ជីសាឡើងវិញ អាចត្រូវធ្វើឡើងដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយភ្នាក់ងារតំណាងរបស់គាត់ក្នុងរយៈពេលប្រាំមួយ(៦)ខែ មុនការផុតកំណត់នៃការចុះបញ្ជី។

២- ការចុះបញ្ជីសាឡើងវិញត្រូវធ្វើឡើង ដោយមានការបង់កម្រៃក្នុងការចុះបញ្ជីសាឡើងវិញ ក្នុងរយៈពេលដែលបានកំណត់ដូចមានចែងក្នុងចំណុច ១ នៃប្រការនេះ ឬក្នុងរយៈពេលអនុគ្រោះ ចំនួនប្រាំមួយ(៦)ខែ ដូចមានចែងក្នុងមាត្រា ១០៩ នៃច្បាប់ ដោយមានការបង់កម្រៃបន្ថែម លើការយឺតយ៉ាវ។

៣- ការចុះបញ្ជីសាឡើងវិញនៃគំនូរឧស្សាហកម្ម ត្រូវកត់ត្រានៅក្នុងបញ្ជី និងត្រូវបោះពុម្ពផ្សាយ។

៤- មន្ត្រីកាន់កាប់បញ្ជីត្រូវដំណើរការចេញវិញ្ញាបនបត្រចុះបញ្ជីសាឡើងវិញ ជូនដល់ម្ចាស់គំនូរឧស្សាហកម្ម ដែលក្នុងនោះមាន ៖

ក- លេខចុះបញ្ជីនៃគំនូរឧស្សាហកម្ម

ខ- កាលបរិច្ឆេទនៃការចុះបញ្ជីសាឡើងវិញ និងកាលបរិច្ឆេទនៃការផុតកំណត់

គ- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់ដែលបានចុះបញ្ជី និង

ឃ- ការបញ្ជាក់អំពីប្រភេទនៃផលិតផល ដែលគំនូរឧស្សាហកម្មត្រូវបានចុះបញ្ជីរួចហើយ។

**ប្រការ២១.-**

ការប្តូរម្ចាស់កម្មសិទ្ធិ និងកិច្ចសន្យាអាជ្ញាប័ណ្ណនៃគំនូរឧស្សាហកម្ម ត្រូវអនុវត្តដូចខាងក្រោម ៖

១- អនុលោមតាមមាត្រា ១១៤ នៃច្បាប់ សំណើសុំធ្វើការកត់ត្រាការប្តូរម្ចាស់កម្មសិទ្ធិ នៃគំនូរឧស្សាហកម្ម ដែលបានចុះបញ្ជីស្របតាមច្បាប់ ឬធ្វើការកត់ត្រាការប្តូរម្ចាស់កម្មសិទ្ធិ នៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ត្រូវបំពេញតាមគំរូពាក្យសុំដែលកំណត់ រួចដាក់ជូនមន្ត្រីកាន់កាប់បញ្ជី។

២- ការបោះពុម្ពផ្សាយស្តីពីការប្តូរម្ចាស់កម្មសិទ្ធិ ត្រូវបញ្ជាក់អំពី ៖

ក- ចំណងជើងនៃគំនូរឧស្សាហកម្មដែលបានការពារ

ខ- កាលបរិច្ឆេទសុំចុះបញ្ជី កាលបរិច្ឆេទអាទិភាព (ប្រសិនបើមាន) និងកាលបរិច្ឆេទ នៃការចុះបញ្ជី

គ- ម្ចាស់កម្មសិទ្ធិ និងម្ចាស់កម្មសិទ្ធិថ្មី និង

ឃ- លក្ខណៈនៃការប្តូរម្ចាស់កម្មសិទ្ធិ។

៣- កិច្ចសន្យាអាជ្ញាប័ណ្ណដែលបានដាក់ជូន ដើម្បីកត់ត្រាយោងតាមមាត្រា ១១៥ នៃច្បាប់ ត្រូវបង់កម្រៃសេវាតាមការកំណត់។

**ប្រការ២២.-**

ភ្នាក់ងារត្រូវអនុវត្តដូចខាងក្រោម ៖



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

១- អនុលោមតាមមាត្រា ១១៦ នៃច្បាប់ ការចាត់តាំងភ្នាក់ងារតំណាងត្រូវធ្វើឡើងតាមរយៈលិខិតប្រគល់សិទ្ធិ ដែលត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យសុំ ឬដោយអ្នកដាក់ពាក្យសុំម្នាក់ៗ ប្រសិនបើមានអ្នកដាក់ពាក្យសុំលើសពីមួយនាក់។ អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ត្រូវចាត់ទុកថាជាអាសយដ្ឋានទាក់ទង ដើម្បីបញ្ជូនដំណឹងទៅបុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ដែលបានចាត់តាំងភ្នាក់ងារនោះ សម្រាប់គោលបំណងទាំងឡាយដែលពាក់ព័ន្ធទៅនឹងច្បាប់ និងប្រកាសនេះរួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ។

២- លិខិតប្រគល់សិទ្ធិឱ្យភ្នាក់ងារ ដូចមានចែងក្នុងចំណុច១ នៃប្រការនេះ ត្រូវភ្ជាប់មកជាមួយសំណុំលិខិតស្នើសុំ ឬដែលត្រូវប្រគល់ក្នុងរយៈពេលពីរ(២)ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី នៃសំណុំលិខិតស្នើសុំនោះ។

៣- ប្រសិនបើការចាត់តាំងភ្នាក់ងារ មិនត្រូវបានអនុវត្តដូចមានចែងក្នុងចំណុច ២ នៃប្រការនេះទេ ហើយមិនស្របតាមមាត្រា ១១៦ នៃច្បាប់ ចំណាត់ការជានីតិវិធីណាមួយ ដែលធ្វើដោយភ្នាក់ងារក្រៅពីការដាក់សំណុំលិខិតស្នើសុំចុះបញ្ជី ត្រូវចាត់ទុកថាមិនបានធ្វើឡើយ។

៤- ការតម្រូវនានា ពាក់ព័ន្ធភ្នាក់ងារតំណាងរបស់អ្នកដាក់ពាក្យសុំ ដូចមានចែងក្នុង ចំណុច១ នៃប្រការនេះ ត្រូវចែងដោយបទប្បញ្ញត្តិដោយឡែក ដែលកំណត់ដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ២៣.-**

កាលណាថ្ងៃចុងក្រោយសម្រាប់អនុវត្តសកម្មភាពណាមួយ ឬដំណើរចំណាត់ការណាមួយប៉ះចំថ្ងៃដែលក្រុមហ៊ុន និងនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី មិនធ្វើការបម្រើសាធារណជន ត្រូវចាត់ទុកថាស្របច្បាប់ ចំពោះការអនុវត្តសកម្មភាព ឬដំណើរការនៅថ្ងៃដែលក្រុមហ៊ុន ឬនាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ធ្វើការបម្រើសាធារណជននៅថ្ងៃបន្ទាប់ពីថ្ងៃឈប់នោះ។

**ប្រការ២៤.-**

ការដកស្រង់ព័ត៌មានពីបញ្ជី និងការកែតម្រូវកំហុស ត្រូវអនុវត្តដូចខាងក្រោម ៖

១- ការស្នើសុំច្បាប់ចម្លង ដែលមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម នៃការដកស្រង់ព័ត៌មានពីបញ្ជី ឬការស្នើសុំថតចម្លងឯកសារផ្សេងៗ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី។

២- យោងតាមមាត្រា ១២០ នៃច្បាប់ ការកែតម្រូវកំហុសអាចត្រូវបានធ្វើឡើង ដោយមន្ត្រីកាន់កាប់បញ្ជី នៅពេលដែលបានទទួលសំណើជាលាយលក្ខណ៍អក្សរ ហើយបានបំពេញលក្ខខណ្ឌទាំងឡាយ ដែលមន្ត្រីកាន់កាប់បញ្ជីពិនិត្យឃើញថាសមស្រប ឬតាមគំនិតផ្តួចផ្តើមផ្ទាល់របស់មន្ត្រីកាន់កាប់បញ្ជី។ ការកែតម្រូវទាំងឡាយដែលបានធ្វើឡើង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅបុគ្គលពាក់ព័ន្ធទាំងឡាយ ហើយក្នុងករណីចាំបាច់ ត្រូវបោះពុម្ពផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី។

**ប្រការ២៥.-**

សវនាការ ត្រូវអនុវត្តដូចខាងក្រោម ៖

១- មុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិណាមួយ ដែលបានផ្តល់ឱ្យមន្ត្រីកាន់កាប់បញ្ជីដោយច្បាប់ ឬដោយប្រកាសនេះ ចំពោះបុគ្គលណាម្នាក់ដោយមិនអនុគ្រោះ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅបុគ្គលនោះ អំពីឱកាសសម្រាប់សវនាការ ហើយបញ្ជាក់អំពីពេលវេលាដែលកម្រិតមិនតិចជាងមួយ(១)ខែ សម្រាប់ការដាក់ពាក្យសុំធ្វើសវនាការនោះ។

២- ពាក្យសុំធ្វើសវនាការត្រូវធ្វើជាលាយលក្ខណ៍អក្សរ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ឧទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

៣- នៅពេលទទួលពាក្យសុំធ្វើសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទ និងពេលវេលាធ្វើសវនាការមិនតិចជាងរយៈពេលពីរ(២)សប្តាហ៍ មុនកាលបរិច្ឆេទកំណត់ធ្វើសវនាការទៅបុគ្គលដែលបានដាក់ពាក្យសុំ និងបុគ្គលពាក់ព័ន្ធផ្សេងៗទៀត។

**ប្រការ២៦.-**

សេវាកម្មដោយសំបុត្រ ត្រូវអនុវត្តដូចខាងក្រោម៖

១- សេចក្តីជូនដំណឹងណាមួយ សំណុំលិខិតស្នើសុំ ឬឯកសារផ្សេងៗទៀត ដែលបានធ្វើតាមរយៈប្រៃសណីយ៍ ឬមធ្យោបាយផ្សេងទៀតជូនដល់មន្ត្រីកាន់កាប់បញ្ជី ត្រូវចាត់ទុកថា បានប្រគល់ បានផ្តល់ បានធ្វើ ឬបានដាក់សំណុំលិខិតស្នើសុំ នៅពេលដែលឯកសារទាំងនោះ ត្រូវបានប្រគល់តាមរបៀបធម្មតានៃប្រៃសណីយ៍ ឬមធ្យោបាយផ្សេងទៀតដែលអាចយកជាការបាន។ ដើម្បីបញ្ជាក់ជាភស្តុតាងអំពីការបញ្ជូននេះ ត្រូវតែបង្ហាញភស្តុតាងគ្រប់គ្រាន់ថា លិខិតដែលរួមមានសេចក្តីជូនដំណឹង សំណុំលិខិតស្នើសុំ ឬឯកសារផ្សេងៗខាងលើនោះ បានសរសេរអាសយដ្ឋានយ៉ាងត្រឹមត្រូវ និងបានធ្វើតាមលិខិតអនុសិដ្ឋ។

២- ចំណុច១ នៃប្រការនេះ មិនត្រូវបានយកមកអនុវត្ត ចំពោះការយល់ព្រមទទួលស្គាល់កាលបរិច្ឆេទសុំចុះបញ្ជីឡើយ។

**ប្រការ២៧.-**

ភស្តុតាង ត្រូវអនុវត្តដូចខាងក្រោម ៖

១- អនុលោមតាមប្រកាសនេះ ភស្តុតាងដែលត្រូវដាក់ជូនពិនិត្យ ត្រូវធ្វើឡើងតាមរយៈលិខិតសច្ចាប្រណិធាន។

២- ក្នុងករណីដោយឡែកណាមួយ ប្រសិនបើពិនិត្យឃើញថាជាការសមស្រប មន្ត្រីកាន់កាប់បញ្ជីអាចទទួលយកភស្តុតាងផ្ទាល់មាត់ជំនួស ឬបន្ថែមលើភស្តុតាងខាងលើ និងត្រូវអនុញ្ញាតឱ្យសាក្សីណាមួយអាចចូលរួមធ្វើការចោទសួរឆ្លើយឆ្លង អំពីលិខិតសច្ចាប្រណិធាន ឬលិខិតប្រកាសរបស់គេ។

**ប្រការ២៨.-**

លិខិតប្រកាសស្របច្បាប់ ត្រូវអនុវត្តដូចខាងក្រោម ៖

១- លិខិតប្រកាសស្របច្បាប់ ឬលិខិតសច្ចាប្រណិធានណាមួយ ដែលដាក់ជូនសម្រាប់ពិនិត្យស្របតាមច្បាប់ និងប្រកាសនេះ ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីណាម្នាក់ ដែលបានទទួលសិទ្ធិតាមច្បាប់ នៅទីកន្លែងណាមួយនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចាត់ចែងការធ្វើសច្ចាប្រណិធាន សម្រាប់គោលបំណងនៃដំណើរការស្របតាមផ្លូវច្បាប់។

២- លិខិតប្រកាសស្របច្បាប់ ឬលិខិតសច្ចាប្រណិធានដែលធ្វើនៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីស្ថានកុងស៊ុល ឬមន្ត្រីស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ។

**ប្រការ២៩.-**

ចំណុចពិសេសទាំងឡាយរបស់គំនូរឧស្សាហកម្ម និងដំណើរការដទៃទៀត អនុលោមតាមច្បាប់ និងព័ត៌មានណាមួយផ្សេងទៀតដែលតម្រូវឱ្យបោះពុម្ពផ្សាយ អនុលោមតាមច្បាប់ ឬប្រកាសនេះ រួមទាំងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ត្រូវបោះពុម្ពផ្សាយតាមការណែនាំរបស់មន្ត្រីកាន់កាប់បញ្ជី នៅក្នុងព្រឹត្តិបត្រផ្លូវការ ដែលនឹងត្រូវរៀបចំឡើង។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ប្រការ៣០.-**

កម្រៃសេវាដែលត្រូវបង់សម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្ម ដូចមានចែងក្នុងប្រកាសនេះ ត្រូវអនុវត្តតាមការកំណត់ដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៣១.-**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម មានសមត្ថកិច្ចបង្កើតយន្តការដោះស្រាយទំនាស់ ពាក់ព័ន្ធនឹងការចុះបញ្ជីគំនូរឧស្សាហកម្មតាមការចាំបាច់។

**ប្រការ៣២.-**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ត្រូវសហការជាមួយអង្គការជាតិ និងអន្តរជាតិ និងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការការពារកម្មសិទ្ធិឧស្សាហកម្ម និងអភិវឌ្ឍប្រព័ន្ធចុះបញ្ជីគំនូរឧស្សាហកម្ម។

**ប្រការ៣៣.-**

ប្រកាសនេះមានភ្ជាប់ដោយឧបសម្ព័ន្ធ សម្រាប់ការដាក់ពាក្យសុំ គឧ១, គឧ២, គឧ៣, គឧ៤, គឧ៥ , គឧ៦, គឧ៧, គឧ៨, គឧ៩ និង គឧ១០។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ៣៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣៥.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ប្រធាននាយកដ្ឋាននីតិកម្ម គ្រប់អង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត និងរូបវន្តបុគ្គល ឬនីតិបុគ្គលដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ៤ រោច ខែ ផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**កន្លែងទទួល៖**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៣៥
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com